ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៣. សរ

# សារាចរ

## ស្តីពី

## ការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់ តាមរាជធានី ទីក្រុង និងទីប្រជុំជន

សារាចរនេះ មានគោលដៅដោះស្រាយចំពោះតែសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់ ។

គោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងឯកសារបឋមស្តីពីក្របខ័ណ្ឌយុទ្ធសាស្ត្រគោលនយោបាយដីធ្លី នាខែកញ្ញា ឆ្នាំ២០០២ បានលើកឡើងអំពីសិទ្ធិកាន់កាប់ដីធ្លីបណ្តោះអាសន្ន និងមានរយៈពេលកំណត់ចំពោះអ្នកតាំងទីលំនៅខុសច្បាប់ និងសំណង់អនាធិបតេយ្យដែលបានកើតជាបន្តនៅរាជធានី ទីរួមខេត្ត និងទីប្រជុំជនមួយចំនួន ។ តាមការសិក្សាសំណង់បណ្តោះអាសន្នដែលបានសាងសង់ដោយខុសច្បាប់តាមទីក្រុង ទីប្រជុំជន ដែលបានកើតមានកន្លងមក បណ្តាលមកពីកត្តាជាច្រើនមានជាអាទិ៍ កំណើនប្រជាជន ការធ្វើមាតុភូមិនិវត្តន៍នៃគ្រួសារភៀសខ្លួន និងភៀសសឹកក្នុងដំណាក់កាលមុនឆ្នាំ១៩៩៨ នៅពេលដែលប្រទេសជាតិពុំទាន់មានសុខសន្តិភាពពេញលេញ ការបាត់បង់ដីធ្លីដោយគ្រោះធម្មជាតិ និងកត្តាផ្សេងៗទៀតជាពិសេសកត្តាចំណាកស្រុកពីតំបន់ជនបទទៅកាន់តំបន់ ទីក្រុងដើម្បីស្វែងរកការងារធ្វើនៅតំបន់ថ្មី ដែលមានការរីកចម្រើនឆាប់រហ័សនៃវិស័យឧស្សាហកម្ម សេវាកម្ម និងនគរូបនីយកម្ម ។

ជាបទពិសោធន៍មួយដ៏ល្អ ក្រោមការឧបត្ថម្ភគាំទ្រហិរញ្ញវត្ថុផ្ទាល់របស់ប្រមុខរាជរដ្ឋាភិបាល អាជ្ញាធររាជធានីបានបំផុសដឹកនាំចលនាសហគមន៍អ្នកក្រីក្រ និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន កសាងបាននូវមូលនិធិមួយហៅថា " មូលនិធិអភិវឌ្ឍកាត់បន្ថយភាពក្រីក្រក្នុងទីក្រុង " ដែលមកដល់ខែឧសភា ឆ្នាំ២០១០ មានទឹកប្រាក់ ១ ៣២០ (មួយពាន់បីរយម្ភៃ)លានរៀល សម្រាប់ផ្តល់ជាប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុដល់គ្រួសារក្រីក្រ យកទៅប្រើប្រាស់ដើម្បីស្តារ និងបង្កើនចំណូលគ្រួសារ និងកែលម្អជីវភាព ។

ក្នុងគោលដៅដោះស្រាយបញ្ហាខាងលើ រាជរដ្ឋាភិបាលដាក់ចេញនូវសារាចរនេះដើម្បីណែនាំដល់អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងស្ថាប័នពាក់ព័ន្ធ អំពីនីតិវិធីដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់ ដែលបានកើតនៅតាមទីក្រុង និងទីប្រជុំជន ដោយត្រូវអនុវត្តវិធានការដូចខាងក្រោម ៖

**១-ការស្រង់ទិន្នន័យជាក់លាក់អំពីចំនួនទីតាំងសំណង់បណ្តោះអាសន្ន**

ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ត្រូវជំរុញឱ្យក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ឱ្យចាត់តាំងក្រុមការងារវាលតាមឃុំ សង្កាត់ ដោយមានការចូលរួមជាសមាជិកចំពោះកិច្ច ពីតំណាងសហគមន៍ ប្រជាជនក្នុងមូលដ្ឋាន និងសង្គមស៊ីវិល ដើម្បីធ្វើការស្រង់ទិន្នន័យចំនួនទីតាំងសំណង់បណ្តោះអាសន្នទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ទីតាំងនៃសំណង់បណ្តោះអាសន្នទីមួយៗ ត្រូវមានស្នាមមេដៃពីគ្រប់សមាជិកនៃក្រុមការងារដែលត្រូវបានចុះស្រង់ទិន្នន័យ ហើយចងក្រងជាស្ថិតិរួមមួយសម្រាប់ជាមូលដ្ឋានក្នុងការស្វែងរកដំណោះស្រាយទៅតាមករណី និង តាមដំណាក់កាល។

## ២-ការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ទីតាំងដីដែលសំណង់បណ្តោះអាសន្នតាំងនៅ

ក្រោយពីការស្រង់ស្ថិតិគ្រប់ទីតាំងសំណង់បណ្តោះអាសន្ន ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ដោយមានការចូលរួមជាសមាជិកចំពោះកិច្ច ពីតំណាងសហគមន៍ប្រជាជនក្នុងមូលដ្ឋាន និងសង្គមស៊ីវិល ត្រូវជួបប្រជុំពិនិត្យ និង ពិភាក្សាលើភាពត្រឹមត្រូវនៃស្ថិតិទីតាំងនីមួយៗ ដើម្បីសម្រេចបញ្ចូលទិន្នន័យទីតាំងនោះទៅក្នុងផែនទីឃុំ សង្កាត់ដែលមានមាត្រដ្ឋានធំ។ ផ្អែកលើទីតាំងជាក់ស្តែងនីមួយៗ ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ និងតំណាងសហគមន៍ ប្រជាជនក្នុងមូលដ្ឋាន សង្គមស៊ីវិលជាសមាជិកចំពោះកិច្ច ត្រូវធ្វើការកំណត់ទីតាំងនីមួយៗ ដោយផ្អែកលើលក្ខណៈរូបវន្តនៃដី ជា៖

-ដីដែលបានប្រើប្រាស់ជា : សួនសាធារណៈ លំហសាធារណៈ ដីឯកជនរបស់រដ្ឋ ដីរបស់បុគ្គលឯកជន ឬរបស់ក្រុមហ៊ុន ដីវត្តអារាម ។ល។

-ដីដែលមានផែនការប្រើប្រាស់រួចហើយសម្រាប់ : ធ្វើសួនសាធារណៈ ធ្វើប្រព័ន្ធលូ ឬប្រឡាយបង្ហូរទឹក បណ្តាញផ្លូវថ្នល់ តំបន់ពាណិជ្ជកម្ម តំបន់ឧស្សាហកម្ម តំបន់លំនៅឋាន តំបន់ទេសចរណ៍ ។ល។

-ទីតាំងដែលអាចបង្កគ្រោះថ្នាក់ដល់អ្នកស្នាក់នៅ : ជិតទីវាលចាក់សម្រាម លើចិញ្ចើមផ្លូវ ជិតប្រឡាយបង្ហូរទឹក លើដីចំណីផ្លូវថ្នល់ ផ្លូវរថភ្លើង លើទំនប់ការពារទឹកជំនន់ ច្រាំងទន្លេ ស្ទឹង ព្រែក លើដំបូល ទៃវ៉ាស់ ។ល។

ចំពោះផែនទីនៃទីតាំងសំណង់បណ្តោះអាសន្ន ត្រូវសម្គាល់ដោយប្រើពណ៌ផ្សេងៗឬប្រើនិមិត្តសញ្ញាបច្ចេកទេសដើម្បីបញ្ជាក់លក្ខណៈរូបវន្តនៃដីតាមប្រភេទដែលសំណង់បណ្តោះអាសន្នតាំងនៅ ដូចបានរៀបរាប់ខាងលើ ហើយត្រូវមានស្នាមមេដៃទទួលស្គាល់ដោយក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ តំណាងសហគមន៍ប្រជាជនក្នុងមូលដ្ឋាន សង្គមស៊ីវិលជាសមាជិកចំពោះកិច្ច សម្រាប់ប្រើប្រាស់ជាឧបករណ៍ក្នុងការពិភាក្សាស្វែងរកដំណោះស្រាយ និង ត្រូវផ្សព្វផ្សាយជាសាធារណៈ ដើម្បីទប់ស្កាត់ការចូលទន្ទ្រានកាន់កាប់ដីរបស់រដ្ឋដោយខុសច្បាប់តទៅទៀត។

បន្ទាប់មក ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវប្រជុំស្វែងរកការឯកភាពគ្នាលើការកាន់កាប់ និងលើចំណាត់ថ្នាក់ដី ជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ ឬជាដីរបស់បុគ្គលឯកជន និងធ្វើរបាយការណ៍ដោយភ្ជាប់ផែនទី ឯកសារណេប មតិឯកភាពគ្នា ឬមិនឯកភាពគ្នា និងយោបល់របស់អង្គប្រជុំ ដើម្បីសុំការសម្រេចពីគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត។ ចំពោះដីរដ្ឋដែលបានធ្វើអត្តសញ្ញាណកម្ម ធ្វើផែនទី និងធ្វើចំណាត់ថ្នាក់ដីដោយមានការឯកភាពគ្នា ឬមានការសម្រេចពីគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត រួចហើយអាជ្ញាធរត្រូវធ្វើការចុះបញ្ជីដីនោះទៅក្នុងសៀវភៅ គោលបញ្ជីដីធ្លី។ ដូច្នេះ ទន្ទឹមនឹងការដោះស្រាយករណីជាក់ស្តែងនីមួយៗ

អាជ្ញាធររាជធានី ខេត្ត ត្រូវយកចិត្តទុកដាក់កសាងជាជំហានៗនូវផែនទីដីរបស់រដ្ឋ ដោយធ្វើការចុះបញ្ជីដីរដ្ឋទុកជាឯកសារមូលដ្ឋាន សម្រាប់ការអនុវត្តដំណោះស្រាយ និងធ្វើការផ្សព្វផ្សាយជាសាធារណៈ ដើម្បីទប់ស្កាត់ការចូលទន្ទ្រានកាន់កាប់ដីរបស់រដ្ឋដោយខុសច្បាប់ទៅថ្ងៃខាងមុខ។

## ៣-ការធ្វើជំរឿនចំនួនគ្រួសារ និងចំនួនប្រជាជនដែលរស់នៅក្នុងទីតាំងសំណង់បណ្តោះអាសន្ន

ផ្អែកលើផែនទីដែលមានដៅទីតាំងសំណង់បណ្តោះអាសន្ន ប្រធានក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ដោយមានតំណាងសហគមន៍ប្រជាជនក្នុងមូលដ្ឋាន និងសង្គមស៊ីវិលជាសមាជិកចំពោះកិច្ចចូលរួមផង ត្រូវចាត់តាំងឱ្យក្រុមការងារវាលតាមឃុំ សង្កាត់គោលដៅ ស្រង់ស្ថិតិសមាជិកគ្រួសារនៅតាមខ្នងផ្ទះនៃទីតាំងនីមួយៗ ដោយមានថតរូបមេគ្រួសារ និងសមាជិកគ្រួសារទាំងអស់សម្រាប់ភ្ជាប់ជាមួយស្ថិតិគ្រួសារ។ ក្នុងស្ថិតិគ្រួសារនីមួយៗ ត្រូវមានបញ្ជាក់ថាជាម្ចាស់សំណង់បណ្តោះអាសន្ន ឬ ជាអ្នកជួល និងមានស្នាមមេដៃពីគ្រប់សមាជិកក្រុមការងារដែលបានចុះផ្ទាល់ ព្រមទាំងមានស្នាមមេដៃមេគ្រួសារ ឬតំណាងគ្រួសារនីមួយៗទុកជាភស្តុតាង។

តារាងស្ថិតិគ្រួសារដែលបានស្រង់រួច ត្រូវបិទផ្សាយជាសាធារណៈក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៅក្នុងទីតាំងសំណង់បណ្តោះអាសន្នសាមី និងនៅសាលា ឃុំ សង្កាត់ ដើម្បីទទួលយកសំណូមពរប្រជាពលរដ្ឋក្នុងមូលដ្ឋាន។

## ៤- ការស្វែងរកដំណោះស្រាយ

ផ្អែកលើមូលដ្ឋានព័ត៌មានដែលប្រមូលបានខាងលើ ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ តំណាងសហគមន៍ប្រជាជនក្នុងមូលដ្ឋាន សង្គមស៊ីវិលជាសមាជិកចំពោះកិច្ចចូលរួមផង ត្រូវប្រជុំពិនិត្យពិភាក្សាសម្រេចជ្រើសរើសដំណោះស្រាយចំពោះករណីជាក់ស្តែងរបស់ទីតាំងសំណង់បណ្តោះអាសន្ននីមួយៗ ដោយត្រូវចាត់ទុកជាអាទិភាពផលប្រយោជន៍សាធារណៈ និងដោយផ្អែកលើលក្ខណៈរូបវន្តនៃទីតាំង និងលើផលប្រយោជន៍របស់ប្រជាពលរដ្ឋភាគច្រើនក្នុង សហគមន៍ ព្រមទាំងភាពចាំបាច់នៃការអភិវឌ្ឍរបស់មូលដ្ឋាន។ ក្រោយការឯកភាពសម្រេចជ្រើសរើសយកដំណោះស្រាយណាមួយ ដូចជាការប្តូរទៅកាន់ទីតាំងថ្មី ឬអភិវឌ្ឍន៍នៅនឹងកន្លែង ជាគោលនយោបាយដទៃទៀត រួចហើយក្រុមការងារនេះត្រូវរៀបចំផែនការអនុវត្ត និងកំណត់ពេលវេលាសម្រាប់អនុវត្តជាក់ស្តែង ហើយត្រូវស្នើសុំសេចក្តីសម្រេចពី គណៈកម្មាធិការគ្រប់គ្រង ដីរដ្ឋថ្នាក់រាជធានី ខេត្ត ។

៤.១-ចំពោះអ្នកស្នាក់នៅជាម្ចាស់សំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលទន្ទ្រានកាន់កាប់ដោយខុសច្បាប់ លទ្ធភាពដោះស្រាយមាន៖

-ការប្តូរទៅទីតាំងថ្មី ក្នុងករណីដែលមិនអាចធ្វើការអភិវឌ្ឍនៅនឹងកន្លែងបាន ឬ

-ការអភិវឌ្ឍនៅនឹងកន្លែង ចំពោះទីតាំងសំណង់បណ្តោះអាសន្នលើដីដីរបស់រដ្ឋដែលទន្ទ្រានកាន់កាប់ដោយខុសច្បាប់ ដែលអាចមាន លក្ខណៈសមស្របសម្រាប់ការអភិវឌ្ឍនេះ ឬ

-ការដោះស្រាយគោលនយោបាយដទៃទៀតតាមការជាក់ស្តែង។

៤.២-ចំពោះអ្នកស្នាក់នៅដែលជាអ្នកជួលពីម្ចាស់សំណង់បណ្ដោះអាសន្នមិនស្របច្បាប់ អ្នកជួលត្រូវដោះស្រាយ ជាមួយម្ចាស់សំណង់ខុសច្បាប់ ហើយគ្មានសិទ្ធិទាមទារសំណងអ្វីមួយពីក្រុមការងារដីរដ្ឋថ្នាក់ ក្រុង ស្រុក ខណ្ឌ ឬពីគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ឬពីរាជរដ្ឋាភិបាលឡើយ។

ប្រសិនបើការពិភាក្សារិះរកដំណោះស្រាយពុំមានការឯកភាពគ្នា ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ និងតំណាងសហគមន៍ប្រជាជនក្នុងមូលដ្ឋាន សង្គមស៊ីវិលដែលជាសមាជិកចំពោះកិច្ច ត្រូវរាយការណ៍ស្នើសុំយោបល់ពីគណៈអភិបាលរាជធានី ខេត្ត ដោយភ្ជាប់នូវរបាយការណ៍បញ្ជាក់អំពីលទ្ធផលនៃការប្រជុំដោះស្រាយមានជាអាទិ៍ មតិភាគច្រើននៃអង្គប្រជុំមតិរបស់សហគមន៍មូលដ្ឋានផ្ទាល់ សំណើផ្សេងៗរបស់សង្គមស៊ីវិល និងមតិសាធារណៈចំពោះសំណើដំណោះស្រាយណាមួយប្រសិនបើមាន។

ចំពោះដំណោះស្រាយណាមួយដែលទទួលបានការឯកភាពគ្នា ត្រូវបិទផ្សាយជាសាធារណៈក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៅក្នុងទីតាំងសំណង់បណ្ដោះអាសន្នសាមី និងនៅសាលាឃុំ សង្កាត់ ដើម្បីជាព័ត៌មានជូនប្រជាពលរដ្ឋក្នុងមូលដ្ឋាន។

## ៥-ការពិភាក្សាសម្របសម្រួលដើម្បីកំណត់គោលនយោបាយ

ចំពោះទីតាំងដែលអាចអភិវឌ្ឍនៅនឹងកន្លែង អភិបាលរាជធានី ខេត្ត ក្រុងត្រូវពិភាក្សាជាមួយភាគីពាក់ព័ន្ធដើម្បីរៀបចំផែនការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ កំណត់វិធីដែលត្រូវរៀបចំទីតាំងជាដីឡូត៍ឬជាផ្ទះ និង/ឬគោលនយោបាយផ្សេងៗ ដែលជួយសម្រួលដល់ការអភិវឌ្ឍជីវភាពរស់នៅ។

ចំពោះទីតាំងដែលមិនអាចអភិវឌ្ឍនៅនឹងកន្លែងបាន ហើយត្រូវរុះរើទៅទីតាំងថ្មីត្រូវរៀបចំផែនការច្បាស់លាស់មុននឹងអនុវត្តដំណោះស្រាយ និង/ឬជួយជាគោលនយោបាយ ដើម្បីសម្រួលដល់ការតាំងទីលំនៅថ្មីរបស់ប្រជាពលរដ្ឋ។

ក្នុងដំណោះស្រាយអភិវឌ្ឍនៅនឹងកន្លែង ឬការប្ដូរទៅទីតាំងថ្មី អ្នកដែលទទួលផលពីដំណោះស្រាយអាចទទួលបាន ៖

១-សិទ្ធិផលុបភោគតាមការព្រមព្រៀង ឬ

២-សិទ្ធិកម្មសិទ្ធិបន្ទាប់ពីបានកាន់កាប់ផ្ទាល់ និងរស់នៅលើទីតាំងនោះមានរយៈពេលយ៉ាងតិច ១០ (ដប់) ឆ្នាំ ជាប់គ្នាគិតពីថ្ងៃទទួលយកដំណោះស្រាយ ឬ

៣-សិទ្ធិជួលមានរយៈពេលកំណត់ និងមានប្រាក់ឈ្នួលអនុគ្រោះ។

## ៦-ហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈមូលដ្ឋានចាំបាច់សម្រាប់គាំទ្រដល់ការរស់នៅ

ក-រាល់ដំណោះស្រាយត្រូវគិតគូរដល់ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈចាំបាច់ជាមូលដ្ឋានសម្រាប់អ្នកមានប្រាក់ចំណូលទាបដូចជា កំណត់ទំហំដីនិង/ឬទំហំផ្ទះតូចល្មម ចៀសវាងការដោះស្រាយដែលអាចជា ការលើកទឹកចិត្ត និងទាក់ទាញឱ្យមានសំណង់បណ្ដោះអាសន្នថ្មី លើដីកាន់កាប់ដោយខុសច្បាប់ថែមទៀត។

៦- ត្រូវរៀបចំជាមុននូវហេដ្ឋារចនាសម្ព័ន្ធនិងសេវាសាធារណៈចាំបាច់ៗ ទាំងសម្រាប់ទីតាំងអភិវឌ្ឍន៍នៅនឹង កន្លែង ទាំងទីតាំងថ្មី មានជាអាទិ៍ ផ្លូវថ្នល់ ទឹកប្រើប្រាស់ លូបង្ហូរទឹក និងសេវាចាំបាច់ឯទៀតៗដូចជាសេវាអប់រំ និងសុខភាព និងត្រូវជួយគិតគូរដល់ប្រភពផ្តល់ការងារធ្វើផងដែរ ។

៧-ការចូលរួមរបស់ភាគីពាក់ព័ន្ធក្នុងការអភិវឌ្ឍ

ដើម្បីអនុវត្តដំណោះស្រាយណាមួយដែលបានទទួលការព្រមព្រៀងពីភាគីពាក់ព័ន្ធ ក្រុមការងារដឹកនាំថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យការរៀបចំទីតាំងមុននឹងឈានដល់ដំណាក់កាលអនុវត្តផែនការសកម្មភាពជាក់ស្តែង ។ គ្រប់ភាគីពាក់ព័ន្ធ ត្រូវបន្តជួយប្រជាពលរដ្ឋ ទាំងករណីរើលំនៅឋានទៅកន្លែងថ្មី ទាំងករណីអភិវឌ្ឍន៍នៅនឹងកន្លែងឱ្យបង្កើតជាសហគមន៍ ឬបន្តដំណើរការសហគមន៍ដែលបានរៀបចំរួចហើយ ដោយជួយរៀបចំឱ្យមានបទបញ្ជាផ្ទៃក្នុង និងការងារសន្សំប្រាក់ របស់សហគមន៍ ដោយផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត ។ ក្នុងបទបញ្ជាផ្ទៃក្នុងនោះ គប្បីកំណត់អំពីរចនាសម្ព័ន្ធនៃការគ្រប់គ្រង សិទ្ធិ និងកាតព្វកិច្ចរបស់សមាជិក និងនីតិវិធីក្នុងការសម្រេចបញ្ហាសំខាន់ៗ ។

អាជ្ញាធរមូលដ្ឋានរួមជាមួយភាគីពាក់ព័ន្ធ ដូចជាដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល អាចរួមចំណែកបំពេញការងារនៅក្នុងដំណោះស្រាយ ទាំងស្មារតី ទាំងសម្ភារៈ ទាំងហិរញ្ញវត្ថុ ចាប់តាំងពីពេលផ្តួចផ្តើម ស្វែងរកលទ្ធភាពកសាងកែលំអហេដ្ឋារចនាសម្ព័ន្ធ ផ្តល់សេវាសាធារណៈចាំបាច់ៗជាមូលដ្ឋាន និងបង្គុលកូលាសម្បត្តិបង្កើត ការងារធ្វើជូនប្រជាពលរដ្ឋទាំងនោះ ។

បន្ថែមលើវិធានការទាំង៧ដែលបានកំណត់ខាងលើ រាជរដ្ឋាភិបាលដាក់បញ្ជាយ៉ាងម៉ឺងម៉ាត់តាមរយៈសារាចរនេះដល់ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធទទួលខុសត្រូវទាំងស្រុងក្នុងការទប់ស្កាត់កុំឱ្យ មានសំណង់បណ្តោះអាសន្នថ្មីលើដី ដែលកាន់កាប់ដោយខុសច្បាប់កើតឡើងជាថ្មីទៀត នៅក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ។

ទទួលបានសារាចរនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការគ្រប់ គ្រងដឹកនាំថ្នាក់រាជធានី ខេត្ត ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១០

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន